# ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រៈ កសិកម្ម និងការអភិវឌ្ឍជនបទ

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ ឯកឧត្តម ណាំ ទុំ និង បណ្ឌិត ថេង វុទ្ធី[១] នៅវគ្គទីបីៈ ក (១) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

នៅកម្ពុជា ក៏ដូចជានៅតាមប្រទេសលូតលាស់តិចជាងគេឯទៀតដែរ ភាពក្រីក្រ ច្រើនកើតមាននៅតំបន់ជនបទ ហើយវាមានកំរិតកាន់តែខ្ពស់នៅតាមតំបន់ជនបទណាដែលពឹងផ្អែកជាចំបងលើកសិកម្ម សំរាប់ទ្រទ្រង់ជីវិត ដោះស្រាយជីវភាពរស់នៅ និងផ្តល់ការងារ ។ ឈរលើទស្សនៈនេះ គេចាំបាច់ត្រូវផ្តល់តួនាទីស្នូលដល់ វិស័យកសិកម្ម និងកែប្រែចំណាប់អារម្មណ៍សើៗ ដែលវិស័យនេះតែងទទួលបានក្នុងពេលកន្លងមក ។

## ការរួមចំណែកនៃវិស័យកសិកម្មដើម្បីកំណើន និងការងារ

តាំងពីដើមមក ការចូលរួមចំណែកនៃវិស័យកសិកម្មនៅក្នុងកំណើន មិនមានស្ថិរភាពទេ និងពេលខ្លះអវិជ្ជមានទៀតផង ។ ធនាគារពិភពលោក បានវាយតំលៃថា ការចូលរួមចំណែកនៃវិស័យកសិកម្មក្នុង កំណើនប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ១៩៩៨-២០០៧ មាន ២% ដែលទាបជាខ្លាំង បើធៀបនឹងកំរិត ៤,៥% នៃវិស័យឧស្សាហកម្ម និង ៤,៨%នៃវិស័យសេវាកម្ម ។ សំរាប់ផលិតផលក្នុងស្រុកសរុប (ផសស)ក្នុងឆ្នាំ២០០៧ វិស័យកសិកម្មរួមចំណែកបានប្រមាណ ២៩% ចំណែកឯវិស័យឧស្សាហកម្មបាន ៣០% និងសេវាកម្ម ៤១% ។ វិស័យកសិកម្ម មានកំណើនយឺតជាង វិស័យឧស្សាហកម្ម និងសេវាកម្ម ប៉ុន្តែតាំងពីដើមរៀងមក បានប្រើកម្លាំងពលកម្មភាគច្រើននៅកម្ពុជា ដូចជាក្នុងឆ្នាំ២០០៧ ៥៩% នៃកម្លាំងពលកម្មសរុប បានប្រកបការងារក្នុងវិស័យកសិកម្ម (ក្រាហ្វិក ១) ។ សម្បត្តិធម្មជាតិ និងចំនួនដ៏ច្រើននៃពលករយកកំរៃទាបក្នុង វិស័យកសិកម្ម ក៏បានផ្តល់ឱ្យប្រទេសកម្ពុជានូវសមត្ថភាពប្រកួតប្រជែងខាងកសិកម្មដែរ ។ ដោយសារមូលហេតុទាំងនេះ ការអភិវឌ្ឍកសិកម្មមានសារសំខាន់ដូចគ្នានឹងការធ្វើឧស្សាហូបនីយកម្មដែរ ។ វិស័យនេះនៅមានសក្តានុពលជាច្រើន ដែលមិនទាន់បានប្រើប្រាស់នៅឡើយ ។

វិបត្តិស្បៀងនៅពេលថ្មីៗ និងវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន បានបង្ហាញច្បាស់ ទោះបីមិនសូវរៀបរយក្តី នូវសក្តានុពល និងសារៈសំខាន់នៃវិស័យកសិកម្មកម្ពុជា។ វិបត្តិស្បៀងបានបង្ហាញពីបែបបទដែលវិស័យកសិកម្ម អាចក្លាយជាចង្កូតនៃនាវាសេដ្ឋកិច្ច ហើយវិបត្តិសេដ្ឋកិច្ច បានបង្ហាញពីដំណើរការដែលវិស័យកសិកម្មក្លាយជា ទូកសង្គ្រោះជីវិត នៅពេលនាវាសេដ្ឋកិច្ចត្រូវលិចលង់ ។

ពិតហើយ វិបត្តិទាំងពីរមានផលប៉ះពាល់ផ្ទុយគ្នាទៅលើពាណិជ្ជកម្ម និងផលិតកម្មកសិកម្ម ។ វិបត្តិស្បៀងបានគំរាមកំហែងដល់សន្តិសុខស្បៀងនៅ

ក្រាហ្វិក ១: ចំណែកការងារ គិតជា %




*ប្រភពៈ ធនាគារពិភពលោក ខែមករា ឆ្នាំ២០០៩*

បណ្តាប្រទេសក្រីក្រ ក៏ពិតមែន ប៉ុន្តែវាក៏ជាកត្តាគេទន្ទឹងយូរមកហើយ ដើម្បីជួយតំលើងថ្លៃកសិផលដែលធ្លាក់ចុះទាប បង្កើតបរិយាកាសអំណោយផលសំរាប់ផលិតករ និងអ្នកនាំចេញ និងប្រោះព្រំឱ្យវិស័យកសិកម្មរស់ឡើងវិញ ។ ជាការខាតបង់សំរាប់ផលិតករ និងអ្នកនាំចេញ ប៉ុន្តែជាផលចំណេញសំរាប់អ្នកប្រើប្រាស់ គឺវិបត្តិនាពេលនេះបានបញ្ចុះថ្លៃទំនិញកសិកម្មវិញ តែមិនទាបដូចមុនទេ ពីព្រោះកំរិតថ្លៃនៅតែខ្ពស់ជាង ថ្លៃជាមធ្យមកាលពីឆ្នាំមុនៗដែរ ។

## ផលប៉ះពាល់នៃវិបត្តិស្បៀងទៅលើកសិកម្ម

តាំងពីឆ្នាំ២០០៦ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ការឡើងថ្លៃម្ហូបអាហារបានបញ្ជូនសញ្ញាអាសន្ន ដល់សាកលលោកទាំងមូល ដោយសារផលវិបាកដ៏ធ្ងន់ធ្ងរចំពោះស្ថានភាពអត់ឃ្លានក្នុងពិភពលោក ។ ការឡើងថ្លៃខ្ពស់កប់ពពក វាផុសចេញពីកត្តាជំរុញ ដូចជាវិបត្តិថាមពល ការប្រមូលផលបានតិច លក្ខខណ្ឌអាកាសធាតុមិនអំណោយផល និង កំណើនការប្រកួតប្រជែងរវាងផលិតកម្មជីវឧស្ម័ន និងស្បៀង ។ នៅឆ្នាំ២០០៧ ផលិតផលកសិកម្មនាំចេញចំបងៗរបស់កម្ពុជា គឺមាន ស្រូវ ដំឡូងឈើ និងកៅស៊ូ បានឡើងថ្លៃដល់ ២២៥ដុល្លារ ៧០ដុល្លារ និង ២០១៦ដុល្លារ ក្នុងមួយតោន ហើយស្រូវ និងកៅស៊ូ បន្តឡើងថ្លៃទៀតរហូតដល់ ត្រីមាសទី៣ ឆ្នាំ២០០៨ ។ ជាក់ស្តែងណាស់ កំណើនថ្លៃនេះ បានជួយជំរុញផលិតកម្ម ។ ពីឆ្នាំ២០០៧ ដល់ ២០០៨ ផលិតកម្មដំឡូងឈើកើនឡើងប្រហែល ១,២លានតោន និងកៅស៊ូកើនពី ៣២.០០០តោន ដល់ ៣៧.០០០តោន ។ ក្នុងពេលជាមួយគ្នា ផ្ទៃដីដាំដុះដំឡូងឈើសរុប កើន ៨៨% និង ដីដាំកៅស៊ូកើន ៣២% ។ ឯផលិតកម្មស្រូវ និងសណ្តែកសៀង ក៏កើនឡើងស្របគ្នានឹងផ្ទៃដីដាំដុះវាដែរ ។ សរុបមក ការនាំចេញផលិតផលកសិកម្មបានស្ទុះឡើងនៅពាក់កណ្តាលឆ្នាំ ២០០៧ (ក្រាហ្វិក ២) ។

១ ឯកឧត្តម ណាំ ទុំ ជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង អភិបាលខេត្តកំពង់ធំ ចំណែកឯ បណ្ឌិត ថេង វុទ្ធី ជាអ្នកសំរបសំរួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន វបសអ ។

ក្រាហ្វិក ២: ការនាំចេញតាមវិស័យ (គិតជាលានដុល្លារ US)




*ប្រភព: ទីចាត់ការគយ និងរដ្ឋាករ ស្រង់ចេញដោយធនាគារជាតិនៃកម្ពុជា*

ក្រាហ្វិក ៣ : ផលប៉ះពាល់លើចំណូលបានពីផលិតផលកសិកម្មជ្រើសរើសមួយចំនួន




*ប្រភព: ផលប៉ះពាល់នៃថ្លៃអាហារខ្ពស់នៅកម្ពុជា (វិបសអ ឆ្នាំ២០០៨) និងតារាងតំលៃផលិតផល ខែមករា ឆ្នាំ២០០៧ ដល់ ២០០៩*

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល នៅលើវិស័យកសិកម្ម

សេដ្ឋកិច្ចសាកលធ្លាក់ចុះ បានបំបាត់និន្នាការអតិផរណាខ្ពស់ ដោយវាបានកាត់បន្ថយតំរូវការសាកល និងធ្វើឱ្យថាមពលធ្លាក់ថ្លៃ ។ នៅឆ្នាំ២០០៨ ផលដំឡូងឈើ និងកៅស៊ូនៅកម្ពុជា ធ្លាក់ថ្លៃជាខ្លាំង មកត្រឹម ៣០ដុល្លារអាមេរិក និង ១០២០ដុល្លារអាមេរិក ក្នុងមួយតោន ឬធ្លាក់ចុះប្រហែល ៥០% ធៀបនឹងកាលពីឆ្នាំទៅ ។ នៅឆ្នាំ២០០៨ ផលិតកម្មដំឡូងឈើ និងកៅស៊ូកើនឡើង ប៉ុន្តែនៅត្រីមាសទី៤ កំណើនផលិតកម្មពីមួយឆ្នាំទៅមួយឆ្នាំបានរួមចុះយ៉ាងខ្លាំងវិញ ។ តម្លៃនាំចេញនៃដំឡូងឈើ និងកៅស៊ូ ធ្លាក់ចុះ ហើយតាមការប៉ាន់ស្មាន ដំឡូងឈើបានបាត់បង់តម្លៃនាំចេញ ៩៥លានដុល្លារ ហើយកៅស៊ូបានបាត់បង់ ៣៧លានដុល្លារ ។ ការនាំចេញសណ្តែកសៀង និងពោត ក៏រងផលប៉ះពាល់ពីវិបត្តិដែរ ។ ប៉ុន្តែចំណុចគួរកត់សម្គាល់ គឺការនាំចេញស្រូវរបស់កម្ពុជា អាចធន់ទ្រាំបាននឹងល្អ ហើយពីឆ្នាំ២០០៧ ដល់ ២០០៨ តម្លៃនាំចេញបានកើនឡើងថែមទៀត ។

ស្ថានភាពខាងលើបង្ហាញច្បាស់ថា វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរជាងគេដល់កសិករធម្មតាៗដែលដាំដំឡូងឈើ និងកៅស៊ូ ។ ចំណាយលើធាតុចូលខ្ពស់ គួបផ្សំនឹងការធ្លាក់ចុះករិតថ្លៃ និងតំរូវការ បានកាត់បន្ថយប្រាក់ចំណេញរបស់ប្រជាកសិករ ។ គេប៉ាន់ស្មានថា នៅឆ្នាំ២០០៨ កសិករដែលដាំដំឡូងឈើត្រូវទទួលការខាតបង់ ហើយកសិករដែលដាំកៅស៊ូ មានប្រាក់ចំណេញថយចុះជាខ្លាំង ។ នៅចុងឆ្នាំ២០០៨ ស្រូវប្រាំង ស្រូវវស្សា ពោត និងសណ្តែកសៀងនៅតែអាចផ្តល់ប្រាក់ចំណេញ ប៉ុន្តែសំរាប់ ស្រូវវស្សា ពោត និងសណ្តែកសៀង ប្រាក់ចំណេញនេះបានថយចុះ(ក្រាហ្វិក ៣) ។ ដោយសារការធ្លាក់ចុះប្រាក់ចំណូល ប្រជាកសិករដែលរងផលប៉ះពាល់ កាន់តែលំបាកជាងមុនក្នុងការប្រមូលទុនវិនិយោគមកវិញ ឬសងបំណុលគេ ។

ទោះបីមានឧបសគ្គរាំងដល់ផលដំណាំសំរាប់នាំចេញក្តី ក៏គេប៉ាន់ស្មានថា វិស័យកសិកម្មកម្ពុជាទាំងមូល មានកំណើន ៤,៥% នៅឆ្នាំ២០០៨ ។

## ឱកាស និង គោលនយោបាយជាសក្តានុពល

គេមិនគួរមើលស្រាលពីសារៈសំខាន់នៃវិស័យកសិកម្មដែលអាចធន់ទ្រាំបានល្អនិងវិបត្តិ ជួយទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ចនេះទេ ។ ក្នុងពេលមានការព្យាករណ៍ទុទិដ្ឋិនិយមនៅគ្រប់កន្លែង កសិកម្មជាវិស័យភ្លឺថ្លាមួយ ដែលទំនងមានដំណើរការរីកចម្រើនបន្តទៀតនៅឆ្នាំនេះ ទោះបីការធ្លាក់ចុះករិតថ្លៃនៅតែចោទជាបញ្ហាក្តី ។ អង្កេតមួយស្តីពីឱកាសល្អមានស្រាប់ និងឱកាសល្អរំពឹងទុក បានបង្ហាញពីសក្តានុពលដ៏ធំធេងនានាដែលបង្កប់នៅក្នុងវិស័យកសិកម្ម និងដែលគេអាចមើលឃើញមួយភាគនៅអំឡុងពេលមានវិបត្តិស្បៀង និងសេដ្ឋកិច្ច ។ ជាបឋម គេរំពឹងថា សំពាធបរិត្តផរណាលើករិតថ្លៃផលិតផលកសិកម្ម នឹងមិនអូសបន្លាយយូរទេ ដោយសារតំរូវការពីចិន ឥណ្ឌា និងតំបន់មជ្ឈិមបូព៌ាទំនងជាកើនឡើងវិញ ។ ទីពីរ កម្ពុជានៅមានលទ្ធភាពពង្រីកផ្ទៃដីដាំដុះយ៉ាងច្រើន ។ ទីបី កិច្ចព្រមព្រៀងទ្វេភាគីជាមួយ បណ្តាប្រទេសនៅមជ្ឈិមបូព៌ា អាហ្វ្រិក និងអាស៊ីបូព៌ា (ជាពិសេស ប្រទេសចិន) នឹងបើកចំហទីផ្សារកាន់តែច្រើន សំរាប់ផលិតផលកសិកម្មកម្ពុជា ។

លក្ខខណ្ឌបឋមក្នុងការចាប់យកឱកាស គឺការអនុវត្តនូវគោលនយោបាយជាអាទិភាពមួយចំនួន ។ អនុសាសន៍មួយដែលតែងមានលើកឡើងជារឿយៗ គឺការបង្កើនវិនិយោគខាងកសិកម្ម ។ ដើម្បីបង្កើនផលិតកម្ម និងផលិតភាព គេត្រូវដោះស្រាយផងដែរនូវបញ្ហា កំណែទម្រង់ដីធ្លី ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ។ ចំពោះកំណែទម្រង់ដីធ្លី ដំណើរការចុះបញ្ជីដីធ្លី ការធានាកម្មសិទ្ធិអចលនទ្រព្យ និង ការកែលំអការបែងចែក និងគ្រប់គ្រងដីធ្លី ត្រូវតែពន្លឿនថែមទៀត ។ ប្រព័ន្ធធារាសាស្ត្រ និងផ្លូវជនបទ ត្រូវកែលំអឡើង ។ គេប៉ាន់ស្មានថា ផលចំណេញពីវិនិយោគលើធារាសាស្ត្រ អាចបានរហូតដល់ពីរដងនៃទឹកប្រាក់វិនិយោគ ។ បណ្តាញផ្លូវថ្នល់ដែលកែលំអរួចនឹងកាត់បន្ថយចំណាយផលិតកម្ម និងតំឡើងករិតថ្លៃនៅកសិដ្ឋាន ។ គេត្រូវផ្តល់កម្ចីកាន់តែច្រើន ជាមួយការប្រាក់កាន់តែទាប និងរយៈពេលសងកាន់តែវែង ដើម្បីជួយសំរួលឱ្យមានវិនិយោគខាងកសិកម្មកាន់តែច្រើន ។ ត្រូវជំរុញផងដែរនូវការប្រើប្រាស់គ្រាប់ពូជមានទិន្នផលខ្ពស់ និងការប្រើប្រាស់ជីឱ្យបានកាន់តែប្រសើរ ។ គេរកឃើញថា កំណើន ១%នៃការប្រើប្រាស់ជីបានត្រឹមត្រូវ នឹងបង្កើនទិន្នផលបាន ០,២២% សំរាប់ស្រូវប្រាំង និង ០,២៧% សំរាប់ស្រូវវស្សា ។ ដើម្បីបង្កើនពាណិជ្ជកម្មកសិកម្ម គេចាំបាច់ត្រូវបន្តកាត់បន្ថយចំណាយលើការដឹកជញ្ជូន អភិវឌ្ឍបច្ចេកវិទ្យាត្រូវប្រើក្រោយពេលប្រមូលផល និងសិក្សាពិនិត្យរកគ្រោងការផ្សេងៗ ដូចជា ការចុះកិច្ចសន្យាធ្វើកសិកម្ម ជាដើម ។ ការកែលំអព័ត៌មានទីផ្សារ ក៏ចាំបាច់ដែរ ។ បច្ចុប្បន្នព័ត៌មានទីផ្សារនៅមានតិច ហើយរឿងនេះបានប៉ះពាល់ដល់ប្រជាកសិករសាមញ្ញ ពីព្រោះដោយសារមិនបានដឹងពីករិតថ្លៃបច្ចុប្បន្ន ពួកគាត់ក៏ងាយត្រូវគេបោកប្រាស់ ។ ដើម្បីអភិវឌ្ឍកសិកម្មដែលអំណោយផលដល់អ្នកក្រ ត្រូវមានការដោះស្រាយ បញ្ហាទាំងនេះជាអាទិភាព ៕

### តើអ្នកបានដឹងទេ ថា

*... ផលិតកម្មជីវឥន្ធនៈ បានប្រកួតប្រជែងជាមួយនឹងផលិតកម្មស្បៀង និងប៉ះពាល់ដល់ករិតថ្លៃទំនិញប្រើប្រាស់សាកល ?* ទោះបីចំណែកនៃជីវឥន្ធនៈនៅក្នុងការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពលសាកលនៅមានតិចតួច និងនៅតែមានតិច (ពី ០,៩%នៃការប្រើប្រាស់ថាមពលដឹកជញ្ជូនសរុបនៅក្នុងឆ្នាំ២០០៨ ដល់ប្រហែល ២,៣% នៅឆ្នាំ២០១៥) កំណើនតំរូវការជីវឥន្ធនៈ ជាពិសេស អេតាណុល បានប៉ះពាល់គួរកត់សំគាល់ទៅលើផលិតកម្ម និងថ្លៃដំណាំ ដូចជា ដំឡូងឈើ ជាដើម ។ គេរំពឹងថា ដំឡូងឈើ នឹងឡើងថ្លៃជាមធ្យម ១១% ដោយសារការពង្រីកផលិតកម្មជីវឧស្ម័ន ។

*ប្រភព : អង្គការស្បៀង និងកសិកម្ម (Food and Agriculture Organization-FAO) 2008*

*...ប្រជាជនកម្ពុជារាប់លាននាក់ អាចកំពុងកាន់កាប់ដីរបស់ខ្លួនដោយស្របច្បាប់ ប៉ុន្តែពុំមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ?* យោងតាមច្បាប់ភូមិបាល ឆ្នាំ២០០១ អ្នកកាន់កាប់ដីដោយស្របច្បាប់មានសិទ្ធិស្នើសុំការចុះបញ្ជីដីធ្លី និងរស់នៅលើដីនោះ រហូតទាល់តែទទួលបានការចុះបញ្ជីដីនោះ ។ ប៉ុន្តែ ទោះបីមានកម្មវិធីរដ្ឋបាល និងគ្រប់គ្រងដីធ្លី ដែលទទួលបានការគាំទ្រពី ម្ចាស់ជំនួយជាច្រើនក្តី ក៏មានការរិះគន់ថា ការចុះបញ្ជីដីធ្លី មានដំណើរការយឺត និងមានលក្ខណៈរើសអើង ។

*ប្រភព: ក្រុមការងារលើដីធ្លី និងសំណង់នៅកម្ពុជា (Land and Housing Working Group Cambodia) 2009*